# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលនយោបាយជាតិ

# ស្តីពី

# ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅ

# ព្រះរាជាណាចក្រកម្ពុជា

**រៀបរៀងដោយ៖**

- នាយកដ្ឋានមន្ទីរពេទ្យ
- ក្រុមការងាររៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្រ្តស្តីពីប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា
- ក្រុមរោងជាងជាតិ នៃក្រសួងសុខាភិបាល

**ឆ្នាំ២០១៥**

# មាតិកា

**មាតិកា** ........ ii
**អារម្ភកថា** ........ iii
**បញ្ជីអក្សរកាត់** ........ iv
**គោលនយោបាយជាតិស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ** ........ 1
**១. ទស្សនៈវិស័យ គោលបំណង គោលដៅនិងនិយមន័យឧបករណ៍បរិក្ខារពេទ្យ** ........ 1
**២. សាវតានិងភាពសមស្របក្នុងការបង្កើតគោលនយោបាយជាតិស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា** ........ 1
**៣. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់កណ្តាល ថ្នាក់រាជធានីខេត្ត- និងថ្នាក់ស្រុកប្រតិបត្តិ** ........ 3
៣.១. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់កណ្ដាល ........ 3
៣.២. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ........ 4
៣.៣. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់ស្រុកប្រតិបត្តិ ........ 5
**៤. រចនាសម្ព័ន្ធ និងមុខងាររបស់ដៃគូអនុវត្ត** ........ 6
**៥. ពាក្យបច្ចេកទេសទាក់ទងនឹង ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ** ........ 15
៥.១ ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ........ 15
ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យគឺជាការគ្រប់គ្រង និងថែទាំប្រព័ន្ធដំណើរការរបស់ឧបករណ៍បរិក្ខារ ........ 15
៥. ២ ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ........ 15
៥. ៣ បណ្ដាញគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ........ 16
៥. ៤ ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា (comprehence) ........ 16
៥.៥ វដ្តនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ........ 17
**៦. ស្តង់ដារផ្នែកវិស្វកម្មរោងជាង** / ........ 18
៦.១. ផ្នែកវិស្វកម្ម រោងជាង / ........ 18
៦ .២.ការទទួលខុសត្រូវ ........ 18
**៧. និន្នាការភាពថវិកាសម្រាប់សកម្មភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ** ........ 18
**៨. សេចក្តីណែនាំ និងឯកសារណែនាំសម្រាប់ការគ្រប់គ្រង និងថែទាំឧបករណ៍បរិក្ខារពេទ្យ** ........ 19
**ឯកសារយោង** ........ 20
**សេចក្តីថ្លែងអំណរគុណ** ........ 21
✧ **ឧបសម្ព័ន្ធ-១: ឯកសារណែនាំ និងសេចក្តីណែនាំពាក់ព័ន្ធនឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ** ........ 22

# អារម្ភកថា

ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី២ (២០០៨-២០១៥) ការទទួលខុសត្រូវ ប្រសិទ្ធិភាព គុណភាព សមធម៌របស់ក្រសួងសុខាភិបាលផ្តល់នូវទស្សនៈវិស័យរួមមួយសម្រាប់ធ្វើការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធនានាដើម្បីភាពកាន់តែប្រសើរឡើងនៃស្ថានភាពសុខភាពនិងសុខុមាលភាពរបស់ប្រជាជនកម្ពុជាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រាទី៧២ បានចែងថា សុខភាពរបស់ប្រជាជនត្រូវបានធានា។

បេសកកម្មរបស់ក្រសួងសុខាភិបាលបានគឺ"ផ្តល់មគ្គុទេសភាពសម្រាប់វិស័យសុខាភិបាលទាំងមូលនិងធានាឲ្យមានបរិយាកាសគាំទ្រដល់ការបង្កើនតម្រូវការផ្នែកសុខភាព និងលទ្ធភាពទទួលយកសេវាថែទាំមានគុណភាពប្រកបដោយសមធម៌ ដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់រូបមានលទ្ធភាពទទួលបាននូវសុខភាព និងសុខុមាលភាពកម្រិតអតិបរិមា " ។

ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យល្អគឺជាយុទ្ធសាស្ត្រដ៏សំខាន់ ដើម្បីសម្រេច**បេសកកម្ម**របស់ក្រសួងដែលជាសមាសភាពប្រទាក់ក្រឡាមួយសម្រាប់ផ្តល់សេវាថែទាំសុខភាពប្រកបដោយគុណភាព និងសមភាពនៅគ្រប់កម្រិត និងតំបន់ទាំងអស់ក្នុងប្រទេសកម្ពុជា។ ការរក្សា និងការប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យឲ្យមានស្ថានភាពល្អនៅគ្រប់មូលដ្ឋានសុខាភិបាលបានស្របតាមអាយុកាលមានសារៈសំខាន់ដើម្បីចូលរួមធ្វើរោគវិនិច្ឆ័យជំងឺមានភាពសុក្រឹតហើយដែលមានចែងក្នុងគោលនយោបាយស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។ គោលនយោបាយនេះជាផែនទីបង្ហាញផ្លូវនិងត្រូវបានបង្កើតឡើងដើម្បីដាក់ឲ្យអនុវត្តនៅគ្រប់មូលដ្ឋានសុខាភិបាលក្រោមឱវាទក្រសួងសុខាភិបាលចាប់ពីមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព ។ មូលដ្ឋានសុខាភិបាលដែលហួសពីដែនសមត្ថកិច្ចរបស់ក្រសួងសុខាភិបាលរួមមានក្រសួងផ្សេងៗរបស់រាជរដ្ឋាភិបាលអាចប្រើប្រាស់គោលនយោបាយនេះធ្វើជាមូលដ្ឋានក្នុងការជួយសម្រួលដល់ការគ្រប់គ្រង និងថែទាំឧបករណ៍បរិក្ខារពេទ្យមាននិរន្តរភាព។ មន្ទីរពេទ្យ គ្លីនិកនិងវិស័យឯកជននានា ដែលមានបំពាក់ឬប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យត្រូវអនុវត្តគោលនយោបាយនេះដើម្បីជាគុណប្រយោជន៍សម្រាប់ការផ្តល់សេវាសុខភាពមានសុវត្ថិភាព ។

ក្នុងនាមនាយកគម្រោង MEDEM- 1 និង MEDEM-2 ខ្ញុំសូមសម្តែងនូវការកោតសរសើរដល់ក្រុមគម្រោងMEDED-2 មន្ត្រីនាយកដ្ឋានមន្ទីរពេទ្យ និងសមាជិកក្រុមរោងជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យទាំងអស់ដែលបានចូលរួមចំណែករៀបចំឯកសារគោលនយោបាយដ៏មានសារៈសំខាន់នេះ ។ក្រសួងសុខាភិបាលសំណូមពរដល់ដៃគូអភិវឌ្ឍពាក់ព័ន្ធ ថ្នាក់ដឹកនាំ មន្ត្រីក្រសួងសុខាភិបាល អ្នកគាំទ្រគ្រប់លំដាប់ថ្នាក់ទាំងអស់សូមខិតខំប្រឹងប្រែងរួមគ្នាបន្ថែមទៀតក្នុងការពង្រឹងការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនេះឲ្យទទួលបានជោគជ័យ ។

រាជធានីភ្នំពេញថ្ងៃទី ២២ ខែ [illegible] ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**រដ្ឋលេខាធិការ**

សាស្ត្រាចារ្យ **អេង_ហួត**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| AOP | Annual Operational Plan | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| C/P | Counterpart | មន្រ្តីដៃគូគម្រោង |
| CPA | Complementary Package of Activities | សំណុំសកម្មភាពបង្រ្គប់ |
| DG | Director General | អគ្គនាយកបច្ចេកទេស |
| DDG | Deputy Director General | អគ្គនាយករងបច្ចេកទេស |
| HIS | Health Information System | ប្រព័ន្ធព័ត៌មានសុខាភិបាល |
| HSP | Health Strategic Plan | ផែនការយុទ្ធសាស្រ្តសុខាភិបាល |
| HSSP | Health Sector Strategic Plan | ផែនការយុទ្ធសាស្រ្តវិស័យសុខាភិបាល |
| JICA | Japan International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |
| L-CPA | Lead Complementary Package of Activities | មន្ទីរពេទ្យបង្អែកឈានមុខ |
| L-CPA3/NH | Lead CPA3/National Hospital | មន្ទីរពេទ្យជាតិនិងមន្ទីរពេទ្យបង្អែកកម្រិត៣ឈានមុខ |
| ME | Medical Equipment | ឧបករណ៍បរិក្ខារពេទ្យ |
| MEDEM-1 | Project on Promotion of Medical Equipment Management System | គម្រោងលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ |
| MEDEM-2 | Project for Strengthening Medical Equipment Management at Referral Hospitals | គម្រោងពង្រឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យតាមមន្ទីរពេទ្យបង្អែក |
| MEM | Medical Equipment Manager | ប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ |
| MEM-WG | Medical Equipment Management Working Group | ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ |
| MET | Medical Equipment Technician | អ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យ |
| MDGs | Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្ស |
| MOH | Ministry of Health | ក្រសួងសុខាភិបាល |
| NMCHC | National Center for Maternal and Child Health | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| NWT | National Workshop Team | **ក្រុមរោងជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ** |
| OD | Operational District | ស្រុកប្រតិបត្តិ |
| PHD | Provincial Health Department | មន្ទីរសុខាភិបាលខេត្ត |
| TOR | Terms of Reference | តួនាទី-ភារកិច្ច |
| RH | Referral Hospital | មន្ទីរពេទ្យបង្អែក |
| TWG | Technical Working Group | ក្រុមការងារបច្ចេកទេស |

# គោលនយោបាយជាតិស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

## ១. ទស្សនៈវិស័យ គោលបំណង គោលដៅនិងនិយមន័យឧបករណ៍បរិក្ខារពេទ្យ

### ✧ ទស្សនៈវិស័យ

ឧបករណ៍បរិក្ខារពេទ្យនៅគ្រប់មូលដ្ឋានសុខាភិបាលមានចំនួនគ្រប់គ្រាន់តាមស្តង់ដាររក្សាបានស្ថានភាពនិងដំណើរការប្រក្រតីជាប់ជានិច្ចតាមអាយុកាលដើម្បីចូលរួមផ្តល់សេវាសុខភាពជូនប្រជាជនប្រកបដោយសុវត្ថិភាពនិងមានភាពសុក្រឹត។

### ✧ គោលបំណង

ពង្រឹងគុណភាពសរុបនៃការផ្តល់សេវាសុខភាពតាមរយៈការពង្រឹងប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅតាមមូលដ្ឋានសុខាភិបាលទាំងអស់នៅកម្ពុជា ។

### ✧ គោលដៅ

១. បង្កើតប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យប្រកបដោយប្រសិទ្ធភាពនៅតាមមូលដ្ឋានសុខាភិបាលគ្រប់កម្រិតទូទាំងប្រទេស ។

២. ធានាបែងចែកធនធានមនុស្សសមស្រប ដូចជាប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ និងអ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យ ព្រមទាំងបែងចែកថវិកាសម្រាប់ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យប្រកបដោយប្រសិទ្ធភាព ។

៣. ពង្រឹងប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា និងពង្រីកប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យទៅគ្រប់កម្រិតទាំងអស់ចាប់ពីថ្នាក់ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលរាជធានី-ខេត្ត ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែកទាំងអស់ ។

៤. ពង្រឹង និងធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់ក្រុមរោងជាងជាតិដែលជាអង្គភាពថ្នាក់កណ្តាលក្នុងការអភិបាល ពង្រឹងប្រព័ន្ធគ្រប់គ្រងនិងធ្វើអធិការកិច្ចឧបករណ៍បរិក្ខារពេទ្យគ្រប់ប្រភេទដើម្បីធានាក្នុងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព ។

### ✧ និយមន័យឧបករណ៍បរិក្ខារពេទ្យ

ឧបករណ៍បរិក្ខារពេទ្យសំដៅលើសំភារៈបរិក្ខារឬឧបករណ៍ ប្រដាប់ប្រដាគ្រឿងម៉ាស៊ីន សំភារៈរំងាប់មេរោគ ប្រតិករទាំងឡាយដែលត្រូវប្រើប្រាស់ក្នុងគោលបំណងវេជ្ជសាស្ត្រជាក់លាក់សម្រាប់ការពារ ស្រាវជ្រាវ ធ្វើរោគវិនិច្ឆ័យ ព្យាបាល តាមដានជំងឺ ធ្វើឲ្យសុខភាពអ្នកជំងឺប្រសើរ ឬសម្រាប់ស្តារលទ្ធភាពពលកម្មបណ្តាលមកពីជំងឺឬរបួសផ្សេងៗឬសម្រាប់គាំទ្រដល់ដំណើរការនៃសរីរៈសាស្ត្រ ឬសម្រាប់វាស់វែង ជួសជុលឡើងវិញ បន្សាំកែតម្រូវឬកែច្នៃទម្រង់ឬមុខងាររបស់សារពាង្គកាយមនុស្ស។ក្នុងន័យនេះឧបករណ៍បរិក្ខារពេទ្យមិនអាចសម្រេចជាបឋមដោយសារ ឱសថ ប្រព័ន្ធការពារឬមធ្យោបាយមេតាបូលិកប៉ុន្តែវាជួយឲ្យមធ្យោបាយទាំងនេះសម្រេចបានសកម្មភាព( World Health Organization )។

## ២. សាវតានិងភាពសមស្របក្នុងការបង្កើតគោលនយោបាយជាតិស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា

ចាប់តាំងពីឆ្នាំ១៩៩០នៅប្រទេសកម្ពុជាមិនទាន់មានប្រព័ន្ធគ្រប់គ្រង និងថែទាំឧបករណ៍បរិក្ខារពេទ្យសមស្របនៅឡើយ។ បន្ទាប់ពីភាពចលាចលដ៏ធ្ងន់ធ្ងរត្រូវបានបញ្ចប់ក្នុងឆ្នាំ១៩៩១មក ប្រទេសកម្ពុជាបាន

ទទួលជំនួយឧបករណ៍បរិក្ខារពេទ្យ ពីប្រទេសជាដៃគូអភិវឌ្ឍនិងអង្គការជាច្រើន។ឧបករណ៍បរិក្ខារពេទ្យទាំងនោះ ខ្លះមានស្ថានភាពមិនល្អ ហើយជាទូទៅជាឧបករណ៍ដែលត្រូវបានប្រើប្រាស់រួចហើយប៉ុន្តែមិនមានភ្ជាប់មកជាមួយនូវឯកសារណែនាំ ឬគ្រឿងបន្លាស់ ។លើសពីនេះ ប្រធានគ្រប់គ្រង និងអ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យដែលបានបណ្តុះបណ្តាលមានចំនួនមិនគ្រប់គ្រាន់ នៅតាមមន្ទីរពេទ្យបង្អែកនានា ។ ផលវិបាកបានក្លាយជាស្ថានភាពមួយដោយទុកឧបករណ៍បរិក្ខារពេទ្យចោល អ្នកប្រើប្រាស់ឧបករណ៍មិនអាចកំណត់បានថាអាចប្រើប្រាស់បានដែរឬទេ។ ដូច្នេះឧបករណ៍បរិក្ខារពេទ្យជាច្រើនមិនអាចប្រើប្រាស់បាន អាចបង្កផលប៉ះពាល់បរិស្ថាននិងសុខភាពមនុស្ស សត្វ ។ផ្អែកតាមស្ថានភាពដ៏ធ្ងន់ធ្ងរនេះក្រសួងសុខាភិបាលចាំបាច់បង្កើតប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យហើយបានទទួលជំនួយបច្ចេកទេសពីទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ នៃប្រទេសជប៉ុន(JICA)។ ជាលទ្ធផល គម្រោង MEDEM-1 របស់JICAបានចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០០៦ បន្ទាប់ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកបានអនុវត្តគម្រោងដោយជោគជ័យនិងទទួលបានបទពិសោធន៍ល្អក្នុងឆ្នាំ ២០០០-២០០៥។ក្នុងឆ្នាំ២០០៦ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវបានដាក់ឲ្យអនុវត្តជាមូលដ្ឋាននៅតាមមន្ទីរពេទ្យបង្អែកកម្រិត ៣ ចំនួន ១៨ និងមន្ទីរពេទ្យជាតិចំនួន ៤ ។បច្ចុប្បន្នក្រសួងសុខាភិបាល បានដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រប្រព័ន្ធគ្រប់គ្រងនិងថែទាំឧបករណ៍បរិក្ខារពេទ្យនៅទូទាំងប្រព័ន្ធសុខាភិបាល។យោងតាមលទ្ធផលសម្រេចបាន និងបញ្ហាដែលត្រូវដោះស្រាយដើម្បីធ្វើឲ្យប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យមានភាពប្រសើរឡើង ក្រសួងបានបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅឆ្នាំបន្ទាប់ និងពង្រីកបន្ថែមរហូតដល់មន្ទីរពេទ្យបង្អែកកម្រិត២ចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៩ ។ ផែនការសកម្មភាពនេះត្រូវបានបង្កើតឡើង និងចាប់ផ្តើមអនុវត្តដោយគម្រោងមួយមានឈ្មោះថា គម្រោងពង្រឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យតាមមន្ទីរពេទ្យបង្អែក (MEDEM-2) ។

គោលបំណងរបស់គម្រោង MEDEM-2 គឺបង្កើតប្រព័ន្ធថ្មីមួយដើម្បីផ្សព្វផ្សាយវិធីសាស្ត្រនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យដល់មន្ទីរពេទ្យបង្អែកកម្រិត២ ដែលបានជ្រើសរើសក្រោមគោលគំនិតនៃបណ្តាញគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ និងនៅចុងបញ្ចប់គឺការបង្កើត **"ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា"** ដែលនឹងត្រូវអនុវត្តនៅតាមមន្ទីរពេទ្យបង្អែកកម្រិត២ទាំងអស់។បន្ទាប់មកទៀតនឹងអនុវត្តនៅមន្ទីរពេទ្យបង្អែកកម្រិត១ ។ជាមួយគ្នានេះប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យមូលដ្ឋានត្រូវបានអនុវត្តដោយក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ (MEM-WG) នៅតាមមន្ទីរពេទ្យនីមួយៗហើយនាយកដ្ឋានមន្ទីរពេទ្យបានបង្កើតយន្តការរបាយការណ៍ និងត្រួតពិនិត្យមន្ទីរពេទ្យទាំងនេះនិងក្រុមរោងជាងជាតិលើការថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ (NWT) ។

បទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍និងសមិទ្ធិផលដ៏ធំធេងរបស់គម្រោងMEDEM-1 និង MEDEM-2 បានបង្កើតគោលនយោបាយជាតិ ដែលមានគោលបំណងដើម្បីធ្វើជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់រចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង និងថែទាំឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា ។

សមាសធាតុគោលនយោបាយនេះមានដូចខាងក្រោម៖

- គោលនយោបាយជាតិស្តីពីប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា។
- យុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យព្រមទាំងពង្រឹងបន្ថែមការអភិវឌ្ឍធនធានមនុស្ស អង្គភាព បច្ចេកទេស ការគ្រប់គ្រង និងថវិកា ជាដើម។

- ពង្រឹងការអភិវឌ្ឍន៍សមត្ថភាព និងអង្គភាពរបស់ក្រុមរោងជាងជាតិដែលជាក្រុមអភិបាលថ្នាក់កណ្ដាលទាំងមូល។
- ពង្រឹងបណ្ដាញគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅថ្នាក់កណ្ដាល ថ្នាក់មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ ព្រមទាំងមូលដ្ឋានសុខាភិបាលផ្សេងទៀត។
- ការបង្កើតសេចក្ដីណែនាំ និងឯកសារណែនាំបន្ថែមទៀតតាមតម្រូវការ ។

## ៣. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់កណ្ដាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ

គណៈកម្មការថ្នាក់កណ្ដាល និងគណៈកម្មការថ្នាក់**រាជធានី**-ខេត្តត្រូវបង្កើតឲ្យមាននៅគ្រប់កម្រិតទាំងអស់ សម្រាប់ការរៀបចំផែនការថវិកាដើម្បីថែទាំ ជួសជុលនិងត្រួតពិនិត្យការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យឲ្យដំណើរការដោយរលូននិងប្រកបដោយប្រសិទ្ធភាព។គណៈកម្មការនេះត្រូវបញ្ចូលមន្ត្រីវ័យក្មេងនិងមានសមាសភាពដូចខាងក្រោម៖

### ៣.១. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់កណ្ដាល

| | |
|---|---|
| ១. អគ្គនាយក ឬអគ្គនាយករងបច្ចេកទេសសុខាភិបាល | សហប្រធាន |
| ២. អគ្គនាយក ឬអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សហប្រធាន |
| ៣. ប្រធាននាយកដ្ឋានមន្ទីរពេទ្យ | អនុប្រធាន |
| ៤. ប្រធាន ឬ អនុប្រធាន នាយកដ្ឋាន ថវិកានិងហិរញ្ញវត្ថុ | សមាជិក |
| ៥. ប្រធាន ឬ អនុប្រធាន នាយកដ្ឋាន ផែនការ និង ព័ត៌មានសុខាភិបាល | សមាជិក |
| ៦.ប្រធាន ឬ អនុប្រធាន នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ៧.សាកលវិទ្យាធិការរង ស.វ.ស | សមាជិក |
| ៨. នាយក ឬនាយករងមន្ទីរពេទ្យជាតិ | សមាជិក |
| ៩. នាយក ឬ នាយករង វិទ្យាស្ថានជាតិ | សមាជិក |
| ១០. ប្រធាន ឬអនុប្រធានក្រុមរោងជាងជាតិ | សមាជិក |
| ១១. ប្រធានការិយាល័យសេវាមន្ទីរពេទ្យនិងជីវៈវិស្វកម្មនាយកដ្ឋានមន្ទីរពេទ្យ | លេខាធិការ |

**តួនាទី-ភារកិច្ច មានដូចខាងក្រោម៖**

- អភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។
- ទទួលនិងចុះបញ្ជីសារពើភ័ណ្ឌឧបករណ៍បរិក្ខារពេទ្យពីគ្រប់ប្រភពឲ្យបានច្បាស់លាស់ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។
- ចូលរួមក្នុងការប្រមូល និងបែងចែកធនធានឧបករណ៍បរិក្ខារពេទ្យដល់មូលដ្ឋានសុខាភិបាលគ្រប់កម្រិត។
- ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវប្រព័ន្ធព័ត៌មានស្ដីពីឧបករណ៍បរិក្ខារពេទ្យ ។
- គាំទ្រការបណ្ដុះបណ្ដាលថ្នាក់ខេត្ត និងស្រុកប្រតិបត្តិលើការងារគ្រប់គ្រងថែទាំជួសជុលឧបករណ៍

បរិក្ខារពេទ្យ។

- ធ្វើអធិការកិច្ចឧបករណ៍បរិក្ខារពេទ្យនៅមូលដ្ឋានសុខាភិបាលគ្រប់កម្រិត។
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និង អ្នកផ្តល់ជំនួយលើការងារឧបករណ៍បរិក្ខារពេទ្យ ។

## ៣.២. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់មន្ទីរសុខាភិបាលរាជធានី-ខេត្ត

ត្រូវមានគណៈកម្មការថ្នាក់រាជធានី-ខេត្តនៅរាជធានី-ខេត្តទាំងអស់ដើម្បីអនុវត្តគោលនយោបាយ និង ផែនការយុទ្ធសាស្រ្តសម្រាប់ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យឲ្យមានភាពរលូន និងប្រសិទ្ធភាពដែលមានសមាជិកភាពដូចខាងក្រោម៖

១. ប្រធានឬអនុប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ប្រធាន
២. ប្រធានឬអនុប្រធានមន្ទីរពេទ្យរាជធានី-ខេត្ត សមាជិក
៣. ប្រធានឬអនុប្រធានស្រុកប្រតិបត្តិក្រោមឱវាទ សមាជិក
៤. នាយកឬនាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ សមាជិក
៥. ប្រធានការិយាល័យរដ្ឋបាលមន្ទីរសុខាភិបាលរាជធានីខេត្ត សមាជិក
៦. ប្រធានការិយាល័យគណនេយ្យមន្ទីរសុខាភិបាលរាជធានីខេត្ត សមាជិក
៧. ប្រធានការិយាល័យបច្ចេកទេសមន្ទីរសុខាភិបាលរាជធានីខេត្ត សមាជិក
៨. ប្រធានក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យមន្ទីរពេទ្យរាជធានី-ខេត្ត លេខាធិការ

**តួនាទី-ភារកិច្ច និងការទទួលខុសត្រូវមានដូចខាងក្រោម៖**

- ភ្ជាប់ទំនាក់ទំនងរវាងក្រសួងសុខាភិបាល និងមន្ទីរពេទ្យបង្អែករាជធានី-ខេត្តនិងស្រុកប្រតិបត្តិ។
- អនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្រ្តតាមរយៈផែនការប្រតិបត្តិប្រចាំឆ្នាំលើការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។
- ធានាបែងចែក និងប្រើប្រាស់ធនធានឧបករណ៍បរិក្ខារពេទ្យដែលមានឲ្យបានសមស្របប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព។
- គាំទ្រការអភិវឌ្ឍរបស់ស្រុកប្រតិបត្តិ (ការបណ្តុះបណ្តាលនៅនឹងកន្លែងធ្វើការ និងការសម្របសម្រួល) ។ល។លើការងារឧបករណ៍បរិក្ខារពេទ្យ។
- ត្រួតពិនិត្យ និងវាយតម្លៃ ស្ថានភាពឧបករណ៍បរិក្ខារពេទ្យក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។
- ទទួលនិងចុះបញ្ជីសារពើភ័ណ្ឌឧបករណ៍បរិក្ខារពេទ្យពីគ្រប់ប្រភពឲ្យបានច្បាស់លាស់ ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។
- អនុវត្តលិខិតលេខ០៤១អបស.មពចុះថ្ងៃទី២៩ខែឧសភាឆ្នាំ២០១៥ស្តីពីការលើកកម្ពស់និងការពង្រឹងការគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យរបស់ក្រសួងសុខាភិបាល។

រូបភាព-១: រចនាសម្ព័ន្ធប្រព័ន្ធសុខាភិបាល (រូបភាពដើម: HSP2 រូបភាព-១ )




### ៣.៣. គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់ស្រុកប្រតិបត្តិ

មន្ទីរសុខាភិបាលរាជធានី-ខេត្តត្រូវបង្កើតគណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យថ្នាក់ស្រុក

ប្រតិបត្តិក្រោមឱវាទដើម្បីអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យប្រកបដោយភាពរលូន និងមានប្រសិទ្ធភាព។សមាសភាពរបស់គណៈកម្មការនេះមានដូចខាងក្រោម៖

| | |
|---|---|
| ១. ប្រធានឬអនុប្រធានស្រុកប្រតិបត្តិ | ប្រធាន |
| ២. ប្រធានឬអនុប្រធានមន្ទីរពេទ្យបង្អែកកម្រិត២ និងកម្រិត១ | សមាជិក |
| ៣. ប្រធានឬអនុប្រធានមណ្ឌលសុខភាព | សមាជិក |
| ៤. ប្រធានក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៃមន្ទីរពេទ្យបង្អែកកម្រិត២និងកម្រិត១ | លេខាធិការ |

**តួនាទី-ភារកិច្ចមានដូចខាងក្រោម៖**

- ភ្ជាប់ទំនាក់ទំនងរវាងមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកកម្រិត២/កម្រិត១ និងមណ្ឌលសុខភាព។
- អនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រតាមរយៈផែនការប្រតិបត្តិប្រចាំឆ្នាំលើការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។
- ធានាការបែងចែក និងការប្រើប្រាស់ធនធានឧបករណ៍បរិក្ខារពេទ្យដែលមានឲ្យបានសមស្របប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព ។
- គាំទ្រការអភិវឌ្ឍមូលដ្ឋានសុខាភិបាលទាំងអស់នៅក្រោមស្រុកប្រតិបត្តិ (ការបណ្តុះបណ្តាលនៅនឹងកន្លែង និងការសម្របសម្រួល) ។ល។
- ចុះអភិបាលការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅមន្ទីរពេទ្យបង្អែកកម្រិត២ កម្រិត១ និងមណ្ឌលសុខភាព។
- ត្រួតពិនិត្យ និងវាយតម្លៃ ស្ថានភាពឧបករណ៍បរិក្ខារពេទ្យក្នុងមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។
- ទទួលនិងចុះបញ្ជីសារពើភ័ណ្ឌឧបករណ៍បរិក្ខារពេទ្យពីគ្រប់ប្រភពឲ្យបានច្បាស់លាស់ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។
- អនុវត្តលិខិតលេខ០៤១អបស.មពចុះថ្ងៃទី២៩ខែឧសភាឆ្នាំ២០១៥ស្តីពីការលើកកម្ពស់និងការពង្រឹងការគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យរបស់ក្រសួងសុខាភិបាល។

## ៤. រចនាសម្ព័ន្ធ និងមុខងាររបស់ដៃគូអនុវត្ត

តារាងខាងក្រោមពិពណ៌នាអំពីរចនាសម្ព័ន្ធគម្រោង និងមុខងាររបស់ដៃគូអនុវត្តអនុវត្តនីមួយៗ៖

### រូបភាព-២. រចនាសម្ព័ន្ធ និងមុខងាររបស់ដៃគូពាក់ព័ន្ធ



## ៤.១.ក្រុមរោងជាងជាតិ

ក្រសួងសុខាភិបាលបានបង្កើតក្រុមរោងជាងជាតិថ្នាក់កណ្តាលចំណុះឲ្យនាយកដ្ឋានមន្ទីរពេទ្យជាក្រុមអភិបាល បណ្តុះបណ្តាលបច្ចេកទេស និងរដ្ឋបាលនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។ក្រុមរោងជាងជាតិ មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងស្រុកប្រតិបត្តិត្រូវបានចាត់តាំងដើម្បីទទួលខុសត្រូវក្នុងការផ្តល់ការណែនាំចាំបាច់ខាងផ្នែករដ្ឋបាលនិងបច្ចេកទេស និងគាំទ្រសម្របសម្រួលការរៀបចំបុគ្គលិក និងថវិកា ។ ការបណ្តុះបណ្តាលចាំបាច់ផ្សេងៗសម្រាប់អភិវឌ្ឍសមត្ថភាពក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនឹងត្រូវរៀបចំ និងបង្កើតឡើងក្រោមការសម្របសម្រួលរបស់ក្រុមរោងជាងជាតិ មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងស្រុកប្រតិបត្តិតាមរយៈផែនការប្រតិបត្តិប្រចាំឆ្នាំនៅគ្រប់កម្រិត។

- **បេសកកម្ម និងតួនាទី-ភារកិច្ចរបស់ក្រុមរោងជាងជាតិ**

| |
|---|
| បង្កើត-លើកកម្ពស់និងពង្រឹងប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅគ្រប់មន្ទីរពេទ្យទាំងអស់ក្រោមឱវាទក្រសួងសុខាភិបាលតាមរយៈការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រ ការបង្កើត សេចក្តីណែនាំ ការត្រួតពិនិត្យនិងអភិបាលគាំទ្រការឧបត្ថម្ភផ្នែកបច្ចេកទេសរដ្ឋបាលនិងការគ្រប់គ្រងមន្ទីរពេទ្យគោលដៅដើម្បីលើកកម្ពស់គុណភាពក្នុងការផ្តល់សេវាដល់ប្រជាជនកម្ពុជាទាំងអស់។ |

- **តួនាទី-ភារកិច្ចរបស់ក្រុមរោងជាងជាតិ**(TOR):

១. ចូលរួមអភិវឌ្ឍគោលនយោបាយស្តីពីប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។

២.ទទួលខុសត្រូវលើការកែលម្អនិងធ្វើឲ្យរឹងមាំនូវយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់ពង្រឹងប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជាជាមួយស្ថាប័នពាក់ព័ន្ធនានា។

៣. បង្កើតនិងប្រតិបត្តិបណ្តាញសម្របសម្រួលសហប្រតិបត្តិការនិងការអភិបាលគាំទ្រមន្ទីរពេទ្យទាំងអស់ក្នុងប្រព័ន្ធការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។

៤. ផ្តល់ការណែនាំដល់មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ អង្គភាពសុខាភិបាលនិងមន្ទីរពេទ្យកម្រិត ស.ស.ប ៣,២,១ទាំងអស់អំពីរបៀបប៉ាន់ប្រមាណតម្លៃសម្រាប់ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរួមទាំងការ ថែទាំ ជួសជុលនិងការផ្លាស់ប្តូរឧបករណ៍បរិក្ខារពេទ្យថ្មីដើម្បីស្នើសុំថវិកាក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។

៥.បង្កើតនិងផ្សព្វផ្សាយសេចក្តីណែនាំសម្រាប់ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យការថែទាំនិងការជួសជុសនៅតាមមន្ទីរពេទ្យជាតិមជ្ឈមណ្ឌលជាតិ អង្គភាពសុខាភិបាលនិងមន្ទីរពេទ្យកម្រិតស.ស.ប ៣,២,១។

៦.ផ្តល់ការបណ្តុះបណ្តាល សិក្ខាសាលាផ្នែកបច្ចេកទេស រដ្ឋបាលនិង ការគ្រប់គ្រងដល់មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ អង្គភាពសុខាភិបាល មន្ទីរសុខាភិបាលរាជធានី-ខេត្ត ស្រុកប្រតិបត្តិនិងមន្ទីរពេទ្យកម្រិត ស.ស.ប ៣,២,១ក្នុងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។

៧. ប្រមូលព័ត៌មានឧបករណ៍បរិក្ខារពេទ្យរួមទាំងស្ថានភាពប្រើប្រាស់និងស្ថានភាពដំណើរការពីមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ អង្គភាពសុខាភិបាលនិងមន្ទីរពេទ្យកម្រិតស.ស.ប ៣,២,១។

៨.អភិបាលត្រួតពិនិត្យនិងវាយតម្លៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យដើម្បីផ្តល់ការណែនាំនិងការគាំទ្របន្តទៅដល់មន្ទីរពេទ្យទាំងអស់ទាំងខាងបច្ចេកទេសនិងរដ្ឋបាល។

៩.ចែករំលែកនិងផ្លាស់ប្តូរព័ត៌មានផ្នែកបច្ចេកវិទ្យាថែទាំសុខភាពជាមួយនាយកដ្ឋានពាក់ព័ន្ធ អង្គការជាតិ

និងអន្តរជាតិ។

១០. រៀបចំផែនការប្រតិបត្តិការប្រចាំឆ្នាំសម្រាប់ក្រុមរោងជាងជាតិដើម្បីពង្រឹងរចនាសម្ព័ន្ធរបស់ក្រុមរោងជាងជាតិក្រោមឱវាទនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល។

**ការអធិប្បាយមុខងារ**របស់សមាជិកនីមួយៗត្រូវបានបង្កើតហើយសមាជិកក្រុមត្រូវអនុវត្តតាម ។

ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យមូលដ្ឋាននៅតាមមន្ទីរពេទ្យបង្អែកកម្រិត៣ចំនួន១៨ និងមន្ទីរពេទ្យជាតិចំនួន៤ដែលបានណែនាំដោយគម្រោង MEDEM-1 បានអនុវត្តប្រកបដោយប្រសិទ្ធិភាព ។ សកម្មភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវបានអនុវត្តដោយក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅតាមមន្ទីរពេទ្យបង្អែកនីមួយៗ។ យន្តការនៃការរាយការណ៍ និងការត្រួតពិនិត្យមន្ទីរពេទ្យទាំងនេះត្រូវបានអនុញ្ញាតដោយក្រសួងសុខាភិបាលដូចមានចែងនៅក្នុងតួនាទី-ភារកិច្ចរបស់ក្រុមរោងជាងជាតិ ។

## ៤.២.ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

(រូបភាព ៣ )រចនាសម្ព័ន្ធរបស់ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

**ប្រធានគ្រប់គ្រងឧបករណ៍ពេទ្យ**

ជា នាយករង ឬអនុប្រធានមន្ទីរពេទ្យ

**អនុប្រធានគ្រប់គ្រងឧបករណ៍ពេទ្យ**

ជា ប្រធាន-អនុប្រធាន រដ្ឋបាលឬគណនេយ្យមន្ទីរពេទ្យ

**លេខាអចិន្ត្រៃយ៍**

ជា ប្រធានផ្នែកវិស្វកម្ម ឬ ប្រធានរោងជាងមន្ទីរពេទ្យ

**សមាជិកភាព ៖**

- នាយផ្នែក និង នាយសាល
- វិស្វករឧបករណ៍ពេទ្យ ឬ អ្នកបច្ចេកទេសថែទាំឧបករណ៍ពេទ្យ

✧ គោលគំនិតរបស់ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ៖

- ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវស្វែងយល់ និងធ្វើការគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យឲ្យបានសមស្របដើម្បីឲ្យឧបករណ៍នៅក្នុងមន្ទីរពេទ្យមានស្ថានភាពដំណើរការល្អជានិច្ច។
- អ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យតែម្នាក់ឯងមិនអាចធ្វើការងារគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យបានទេនិងចាំបាច់ត្រូវបង្កើតក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។
- ក្រុមការងារគ្រប់គ្រងឧបករណ៍ពេទ្យត្រូវមានលក្ខណៈពិសេស ៖

ក)សមាជិកក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនីមួយៗត្រូវជួយធ្វើការគ្នាទៅវិញទៅមក ។

ខ)សមាជិកក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនីមួយៗ ត្រូវចែករំលែកព័ត៌មាននៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនិងជួយគ្នាទៅវិញទៅមក។

**(១) ការទទួលខុសត្រូវ៖**

ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវធ្វើការគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យឲ្យបានសមស្របដើម្បីឲ្យឧបករណ៍ដែលកំពុងប្រើប្រាស់នៅក្នុងមន្ទីរពេទ្យមានស្ថានភាពល្អជានិច្ច ។

**(២)ភាពម្ចាស់ការ៖**

ក្រុមការងារគ្រប់គ្រងឧបករណ៍ពេទ្យត្រូវមានភាពម្ចាស់ការ និងតាំងចិត្តអនុវត្តការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅក្នុងមន្ទីរពេទ្យឲ្យបានច្បាស់លាស់ ។

**(៣) ការងារជាក្រុម៖**

សមាជិកក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវធ្វើការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យជាក្រុម ។ ចំណេះដឹងបច្ចេកទេសនិងបទពិសោធន៍របស់មនុស្សម្នាក់មិនអាចបំពេញការងារនេះទទួលបានជោគជ័យទេ ។

- ប្រធានគ្រប់គ្រងឧបករណ៍ពេទ្យត្រូវលើកទឹកចិត្តសមាជិកក្រុមការងារគ្រប់គ្រងឧបករណ៍ពេទ្យ ដើម្បីឲ្យសមាជិកអាចផ្លាស់ប្តូរមតិយោបល់ចំណេះដឹង និងសហការគ្នាក្នុងការបំពេញការងារនេះប្រកបដោយប្រសិទ្ធភាព ។

**(៤) ការណែនាំ និងការបណ្តុះបណ្តាល៖**

- ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវផ្តល់ការណែនាំ និងបណ្តុះបណ្តាលបុគ្គលិកមន្ទីរពេទ្យអំពីរបៀបប្រើប្រាស់ និងថែទាំឧបករណ៍បរិក្ខារពេទ្យ ប្រចាំថ្ងៃឲ្យបានសមស្រប និងជាប្រចាំ ។
- ឧបករណ៍បរិក្ខារពេទ្យដែលខូចភាគច្រើនបណ្តាលពីការប្រើប្រាស់មិនត្រូវតាមការណែនាំ។អាស្រ័យហេតុនេះក្រុមការងារ គ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវ បណ្តុះបណ្តាលជាពិសេសបណ្តុះបណ្តាលមន្ត្រីវ័យក្មេងដែលជាអ្នកប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យដើម្បីបង្ការការខូចខាតដែលកើតឡើងដោយសារការប្រើប្រាស់មិនបានត្រឹមត្រូវ ។

### ៤.២.១.គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិនិងមន្ទីរពេទ្យខេត្ត ៖

- អគ្គនាយក នាយក ឬនាយករងមន្ទីរពេទ្យជាតិ **មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យខេត្ត** ប្រធាន
- ប្រធាន-អនុប្រធាន ការិយាល័យបច្ចេកទេស អនុប្រធាន
- ប្រធាន-អនុប្រធាន ការិយាល័យរដ្ឋបាលឬគណនេយ្យ សមាជិក
- ប្រធានផ្នែកវិស្វកម្ម លេខាអចិន្ត្រៃយ៍

- នាយផ្នែក និង នាយសាល សមាជិក
- វិស្វករ ឬ អ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យ សមាជិក

**តួនាទីនិងភារៈកិច្ចៈ**

**៤.២.១.១ តួនាទីរបស់ប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ**

**ការទទួលខុសត្រូវៈ**

- សម្របសម្រួល និងគ្រប់គ្រងបុគ្គលិកទាក់ទងនឹងការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ទាំងអស់ ដើម្បីប្រើប្រាស់ឧបករណ៍មានលក្ខណៈល្អប្រសើរ មានសេវាថែទាំជួសជុលសមស្រប និងការងាររដ្ឋបាលដំណើរការដោយរលូន ។
- ទទួលខុសត្រូវលើការប្រើប្រាស់ការថែទាំ និងកិច្ចការរដ្ឋបាលទាក់ទងនឹងឧបករណ៍បរិក្ខារពេទ្យទាំងអស់ក្នុងអង្គភាពរបស់ខ្លួន ។
- ទទួលខុសត្រូវលើការងារអភិបាលបុគ្គលិកមន្ទីរពេទ្យទាំងអស់ដែលពាក់ពន្ធ័នឹងការប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យដើម្បីធានាថាឧបករណ៍បរិក្ខារពេទ្យមិនបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ និងបុគ្គលិក ព្រមទាំងអាចផ្តល់លទ្ធផលនៃការធ្វើរោគវិនិច្ឆ័យ ព្យាបាលនិងតាមដានអ្នកជំងឺបានត្រឹមត្រូវ។
- គ្រប់គ្រងនិងសម្របសម្រួលដើម្បីឲ្យក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យអនុវត្តការងារបានដោយរលូននិងត្រូវរាយការណ៍ព័ត៌មានត្រឹមត្រូវស្តីពីឧបករណ៍បរិក្ខារពេទ្យជូនប្រធានមន្ទីរពេទ្យគ្រប់ពេល ។ ក្នុងករណីដែលរោងជាងមិនមានលទ្ធភាព ថែទាំ ជួសជុល ត្រូវស្នើសុំប្រធានអង្គភាពដើម្បីជ្រើសរើស ក្រុមហ៊ុន ឬស្ថាប័ន ដែលមានបច្ចេកទេសសមស្រប ។
- ទទួលនិងចុះបញ្ជីសារពើភ័ណ្ឌឧបករណ៍បរិក្ខារពេទ្យពីគ្រប់ប្រភពឲ្យបានច្បាស់លាស់ ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

**អធិប្បាយមុខងារៈ**

ក) រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ស្តីពីការគ្រប់គ្រងឧបករណ៍ពេទ្យ រួចផ្ញើជូននាយកដ្ឋានមន្ទីរពេទ្យ (ក្រុមរោងជាងជាតិ) នៃក្រសួងសុខាភិបាល ។

ខ) រៀបចំរបាយការណ៍សកម្មភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរួចផ្ញើជូននាយកដ្ឋានមន្ទីរពេទ្យ (ក្រុមរោងជាងជាតិ)នៃក្រសួងសុខាភិបាលបន្ទាប់ពីបានពិនិត្យនិងឯកភាពពីប្រធានមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិនិងមន្ទីរសុខាភិបាលរាជធានី-ខេត្ត

គ)រៀបចំ និងដឹកនាំកិច្ចប្រជុំអំពីការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យជាមួយប្រធាន ផ្នែក-សាលនិងមន្ត្រីពាក់ព័ន្ធលើការប្រើប្រាស់និងការថែទាំឧបករណ៍បរិក្ខារពេទ្យដោយមានការចូលរួមពីប្រធានឬអនុប្រធានមន្ទីរពេទ្យទទួលបន្ទុក ។

ឃ) គ្រប់គ្រងផែនការសកម្មភាពនិងគ្រប់គ្រងសមាជិកក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរបស់ខ្លួន ។

ង) គ្រប់គ្រងថវិកាសម្រាប់ការប្រើប្រាស់ថែទាំនិងជួសជុលឧបករណ៍បរិក្ខារពេទ្យ ។

ច) អភិបាលលើការបណ្តុះបណ្តាល និងការប្រើប្រាស់ឧបករណ៍បរិក្ខាពេទ្យឲ្យបានយ៉ាងតិចមួយត្រីមាសម្តង ។

ឆ) អភិបាលលើការដំឡើង ការសុំជម្រះបញ្ជី និងសកម្មភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យផ្សេងៗទៀត រួមទាំងការរក្សាទុកឧបករណ៍បរិក្ខារពេទ្យដែលខូចឲ្យបានត្រឹមត្រូវ ។

ជ)ស្វែងរកវិធានការដែលទាក់ទងនឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ( ឧទាហរណ៍ៈការទំនាក់ទំនងនិងសម្របសម្រួលខាងក្នុងនិងក្រៅអង្គភាពជាដើម) ។ល។

ឈ) ស្នើសុំប្រធានអង្គភាពសាម៉ីដើម្បី ទិញ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ គ្រឿងបន្លាស់ ឬ ជួសជុល។

ញ)វិភាគតម្រូវការឧបករណ៍បរិក្ខារពេទ្យប្រចាំឆ្នាំ។

## ៤.២.១.២.តួនាទីរបស់អនុប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

### ការទទួលខុសត្រូវៈ

- ទទួលខុសត្រូវលើការងាររដ្ឋបាលឧបករណ៍បរិក្ខារពេទ្យទាំងអស់នៅក្នុងមន្ទីរពេទ្យរួមមានការចុះបញ្ជីសារពើភ័ណ្ឌ ។ល។
- តំណាងឲ្យប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅពេលដែលប្រធានអវត្តមាន។
- រាយការណ៍ព័ត៌មានត្រឹមត្រូវស្តីពីឧបករណ៍បរិក្ខាពេទ្យជូនប្រធានគ្រប់គ្រងគ្រប់ពេល។

### អធិប្បាយមុខងារៈ

ក) ចូលរួមពិនិត្យទទួលឧបករណ៍បរិក្ខារពេទ្យ (ដូចជាការតម្លើងការធ្វើតេស្ត បំពេញទិន្ន័យ ) និងជម្រះបញ្ជីឧបករណ៍បរិក្ខារពេទ្យ។

ខ) ផ្តល់របាយការណ៍ តម្រូវការចាំបាច់នូវគ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និងគ្រឿងបន្លាស់ជូនប្រធានគ្រប់គ្រង។

គ) ជួយជ្រោមជ្រែងការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរបស់ប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។

ឃ) ជួយបុគ្គលិកមន្ទីរពេទ្យទាំងអស់ចំពោះកិច្ចការរដ្ឋបាលណាដែលចាំបាច់សម្រាប់ការប្រើប្រាស់ និងថែទាំឧបករណ៍បរិក្ខារពេទ្យ ។

ង) រៀបចំវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសស្តីពីការប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យសម្រាប់អ្នកប្រើប្រាស់ឧបករណ៍បរិក្ខាពេទ្យ ។

ច) រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆមាស។

ឆ) រៀបចំ និងព្រមទាំងធ្វើរបាយការណ៍អំពីស្ថានភាពឧបករណ៍បរិក្ខារពេទ្យ( ស្ថានភាពដំណើរការ និងស្ថានភាពប្រើប្រាស់) ដោយសហការជាមួយអ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យ ។

ជ) ជួយអ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យធ្វើការត្រួតពិនិត្យនិងកត់ត្រារយៈពេលមធ្យមនៃការជួសជុលឧបករណ៍ពេទ្យ ។

ឈ)រៀបចំរបាយការណ៍ប្រជុំការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ។

ញ) ពិនិត្យ និងគាំទ្រសកម្មភាពការងាររោងជាងថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ។

**សំគាល់:** ស្វែងរកវិធានការដែលត្រូវធ្វើពាក់ព័ន្ធនឹងការងាររដ្ឋបាលឧបករណ៍បរិក្ខារពេទ្យ ។

## ៤.២.១.៣លេខាអចិន្ត្រៃយ៍

### ការទទួលខុសត្រូវ៖

- ទទួលខុសត្រូវរួមក្នុងការថែទាំ ជួសជុល និងការប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យ។
- ជំនួយការបច្ចេកទេសវិស្វកម្ម របស់មន្ទីរពេទ្យ។
- រាយការណ៍ព័ត៌មានស្តីពីស្ថានភាពឧបករណ៍បរិក្ខារពេទ្យជូនអនុប្រធានគ្រប់គ្រងឲ្យបានទៀងទាត់។

### អធិប្បាយមុខងារ ៖

- ពិនិត្យនិងទទួលឧបករណ៍បរិក្ខារពេទ្យ ដូចជាការធ្វើតេស្ត ការធ្វើរបាយការណ៍តំឡើង ។
- ធ្វើផែនការទិញ គ្រឿងប្រើប្រាស់ប្រចាំថ្ងៃ និង គ្រឿងបន្លាស់ ។
- ធ្វើផែនការ សកម្មភាព ប្រចាំឆ្នាំ និង របាយការណ៍ប្រចាំឆមាស។
- រក្សាទុកដាក់ឯកសារទាក់ទងនឹងឧបករណ៍បរិក្ខារពេទ្យទាំងអស់ ។

## ៤.២.១.៤.តួនាទីរបស់វិស្វករឬ អ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យ

### ការទទួលខុសត្រូវ៖

- ទទួលខុសត្រូវក្នុងការថែទាំឧបករណ៍បរិក្ខារពេទ្យ (ថែទាំបង្ការ ជួសជុលសាមញ្ញ) ។ល។ និងរាល់សកម្មភាពទាំងអស់នៅក្នុងរោងជាងថែទាំរបស់មន្ទីរពេទ្យ ។
- ទទួលខុសត្រូវក្នុងការផ្តល់សេវាថែទាំឧបករណ៍ពេទ្យ ដើម្បីឲ្យការប្រើប្រាស់ និងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យប្រព្រឹត្តទៅបានសមស្រប។
- ត្រូវរាយការណ៍ព័ត៌មានផ្សេងៗរបស់ឧបករណ៍បរិក្ខារពេទ្យជូនប្រធានឬអនុប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យគ្រប់ពេល ។

### អធិប្បាយមុខងារ៖

ក)រៀបចំកាលវិភាគថែទាំបង្ការប្រចាំឆ្នាំតាមសៀវភៅមគ្គុទេសក៍ស្តីពីការថែទាំឧបករណ៍បរិក្ខារពេទ្យ ។

ខ)ថែទាំឧបករណ៍បរិក្ខារពេទ្យទាំងអស់ដែលមានក្នុងបញ្ជីសារពើភ័ណ្ឌឧបករណ៍បរិក្ខារពេទ្យរបស់មន្ទីរពេទ្យតាមកាលវិភាគថែទាំបង្ការ ។

គ)ពេលធ្វើការថែទាំបង្ការ ត្រូវបំពេញបញ្ជីត្រួតពិនិត្យការថែទាំដែលមាននៅក្នុងសៀវភៅមគ្គុទេសក៍សម្រាប់ការថែទាំឧបករណ៍ពេទ្យផ្នែក B រួចរក្សាទុកក្នុងក្រូណូ ។

ឃ) អនុវត្តការជួសជុលសាមញ្ញចំពោះឧបករណ៍បរិក្ខារពេទ្យដែលខូច ។

ង)ត្រូវបំពេញកំណត់ត្រាសេវាកម្មឧបករណ៍បរិក្ខារពេទ្យ នៅពេលអនុវត្តសេវាកម្មឧបករណ៍បរិក្ខារពេទ្យ (ការថែទាំបង្ការ ការថែទាំទៀងទាត់ ការជួសជុលសាមញ្ញ ការដំឡើងឧបករណ៍)។ល។

ច)រៀបចំ និងត្រួតពិនិត្យស្ថានភាពឧបករណ៍បរិក្ខារពេទ្យ (ធ្វើបច្ចុប្បន្នភាពឧបករណ៍បរិក្ខារពេទ្យពីរដងក្នុងមួយឆ្នាំ) និងធ្វើរបាយការណ៍ស្ថានភាពឧបករណ៍ពេទ្យ ដោយសហការជាមួយអនុប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។

ឆ)គ្រប់គ្រង និងរៀបចំរោងជាងឲ្យបានសមស្រប ។

ជ)រៀបចំរបាយការណ៍ការវិភាគស្ថានភាពឧបករណ៍បរិក្ខារពេទ្យ។

ឈ)រៀបចំផែនការសកម្មភាពប្រចាំឆ្នាំនិងរបាយការណ៍ប្រចាំឆមាសអំពីសកម្មភាពការងារថែទាំឧបករណ៍បរិក្ខារពេទ្យ និងការងារដទៃទៀត។

ញ)ស្វែងរកវិធានការដែលត្រូវធ្វើពាក់ព័ន្ធនឹងការងារថែទាំឧបករណ៍បរិក្ខារពេទ្យ (រាយការណ៍ជូនប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ) ចំពោះឧបករណ៍បរិក្ខារពេទ្យខូចដែលខ្លួនមិនអាចជួសជុលបាន ។

ដ)ពិនិត្យ និងកត់ត្រារយៈពេលមធ្យមនៃការជួសជុលឧបករណ៍បរិក្ខារពេទ្យគោលដៅ (ឧបករណ៍សំខាន់ៗសម្រាប់ប្រើប្រាស់) ដែលមានក្នុងមន្ទីរពេទ្យរបស់ខ្លួន ។

ឋ) ជួយការងារគ្រប់គ្រងថែទាំឧបករណ៍បរិក្ខារពេទ្យរបស់ប្រធានគ្រប់គ្រង និងអនុប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។

ឌ)ជួយបុគ្គលិកពេទ្យ (អ្នកប្រើប្រាស់ឧបករណ៍បរិក្ខារពេទ្យ) រាល់ការងារចាំបាច់សម្រាប់ការប្រើប្រាស់ និងថែទាំឧបករណ៍បរិក្ខារពេទ្យ ។

**(៣) លក្ខណៈសម្បត្តិ ៖**

**ក) វិស្វករ ៖**

**សមាសភាព:** បុគ្គលិករដ្ឋ ឬបុគ្គលិកជាប់កិច្ចសន្យា។

**សមត្ថភាព:** ជាវិស្វករផ្នែកឧបករណ៍បរិក្ខារពេទ្យ ឬវិស្វករអគ្គីសនី ឬ វិស្វករអេឡិចត្រូនិក ។

**ខ)អ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យ ៖**

**សមាសភាព:** បុគ្គលិករដ្ឋ ឬបុគ្គលិកជាប់កិច្ចសន្យា ។

**សមត្ថភាព:** បុគ្គលិកដែលមានចំណេះដឹងផ្នែកអគ្គិសនី ឬ អេឡិចត្រូនិក ឬ ផ្នែកវេជ្ជសាស្ត្រ ដែលមានសញ្ញាប័ត្របរិញ្ញាប័ត្ររង ។

## ៤.២.១.៥.តួនាទីរបស់ប្រធានផ្នែក ឬ នាយសាល

**ការទទួលខុសត្រូវ៖**

- ទទួលខុសត្រូវលើការងារគ្រប់គ្រង ថែទាំ និង ប្រើប្រាស់ ឧបករណ៍បរិក្ខារពេទ្យក្នុងផ្នែករបស់ខ្លួន ។
- សហការយ៉ាងជិតស្និទជាមួយក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរបស់មន្ទីរពេទ្យ ។

**អធិប្បាយមុខងារ៖**

ក)ចូលរួមប្រជុំស្តីពីការងារគ្រប់គ្រងនិងការថែទាំឧបករណ៍បរិក្ខារពេទ្យតាមកាលវិភាគ ឬបន្ទាន់។

ខ) រាយការណ៍អំពីស្ថានភាពឧបករណ៍បរិក្ខារពេទ្យ(ស្ថានភាពដំណើរការ និង ស្ថានភាពប្រើប្រាស់) ដល់ក្រុមការងារគ្រប់គ្រងនិងការថែទាំឧបករណ៍ពេទ្យ តាមកាលវិភាគ ឬ បន្ទាន់ចាំបាច់។

គ) ចូលរួមការងារគ្រប់គ្រងនិងការថែទាំឧបករណ៍បរិក្ខារពេទ្យក្នុងផ្នែករបស់ខ្លួន។

ឃ) រៀបចំបែងចែកមន្ត្រីដែលពាក់ពន្ធ័ចូលរួមវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសស្តីពីការប្រើប្រាស់និងការថែទាំឧបករណ៍បរិក្ខារពេទ្យ ។

ង )ធ្វើលិខិតស្នើសុំ ជួសជុល សម្ភារៈ ឧបករណ៍បរិក្ខារពេទ្យ ទៅផ្នែកវិស្វកម្ម ឬ រោងជាង ។

### ៤.២.២.គណៈកម្មការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅ មន្ទីរពេទ្យបង្អែកនៃស្រុកប្រតិបត្តិ ៖

| | |
|---|---|
| - អនុប្រធានមន្ទីរពេទ្យ | ប្រធាន |
| - ប្រធាន-អនុប្រធាន ការិយាល័យរដ្ឋបាលមន្ទីរពេទ្យ | អនុប្រធាន |
| - ប្រធានរោងជាង មន្ទីរពេទ្យ | លេខាអចិន្ត្រៃយ៍ |
| - នាយផ្នែក និង នាយសាល | សមាជិក |
| - អ្នកបច្ចេកទេសថែទាំឧបករណ៍ពេទ្យ | សមាជិក |

សមាសភាពគណកម្មការនេះត្រូវទទួលការអភិបាល និងគាំទ្រពីមន្ទីរពេទ្យបង្អែកកម្រិត៣ដែលស្ថិតក្នុងខេត្តតែមួយ ។ ក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យបានតែងតាំងនៅតាមមន្ទីរពេទ្យនីមួយៗ ដើម្បីជានាឲ្យមានការគ្រប់គ្រងថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យបានល្អប្រសើរ ។ ចំនួនសមាជិកក្រុមការងារនេះគឺអាស្រ័យទៅតាមទំហំនិងតម្រូវការរបស់មន្ទីរពេទ្យ ។

## ៥. ពាក្យបច្ចេកទេសទាក់ទងនឹង ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

និយមន័យនៃពាក្យបច្ចេកទេសទាក់ទងនឹងការគ្រប់គ្រង ឧបករណ៍បរិក្ខារពេទ្យមានដូចខាងក្រោម៖

### ៥.១ ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

**ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យគឺជាការគ្រប់គ្រង និងថែទាំប្រព័ន្ធដំណើរការរបស់ឧបករណ៍បរិក្ខារ** ពេទ្យដើម្បីឲ្យឧបករណ៍ដំណើរការបានដោយសុវត្ថិភាព និងមានទំនុកចិត្តក្នុងការធ្វើរោគវិនិច្ឆ័យ ព្យាបាលតាមដាន ទ្រទ្រង់ជីវិតអ្នកជំងឺ ព្យាបាលដោយចលនា ស្តារនីតិសម្បទានិងការសិក្សាស្រាវជ្រាវតាមរយៈប្រព័ន្ធផ្តល់សេវារបស់មន្ទីរពេទ្យ ។ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យធានាថា ឧបករណ៍សម្រាប់ជួយជីវិតអ្នកជំងឺ និងមានតម្លៃថ្លៃនេះនឹងផ្តល់នូវភាពត្រឹមត្រូវ ទំនុកចិត្ត និងព័ត៌មានជាក់លាក់ដល់គ្រូពេទ្យព្យាបាល។ ឧបករណ៍គឺមានសុវត្ថិភាពចំពោះអ្នកជំងឺ និងអ្នកប្រើប្រាស់ ហើយវាអាចប្រើប្រាស់បានយូរតាមអាយុកាល និងមានប្រសិទ្ធភាពក្នុងការថែទាំព្យាបាលអ្នកជំងឺគ្រប់ពេលដោយតម្លៃសមរម្យ ។

### ៥. ២ ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យគឺជាប្រព័ន្ធដែលអាចចែករំលែកព័ត៌មាន ឧបករណ៍បរិក្ខារពេទ្យរវាងថ្នាក់រាជធានី-ខេត្ត និងថ្នាក់កណ្តាល (បែបបទទំនាក់ទំនងព័ត៌មានត្រូវបានបង្កើតឡើង និងដាក់ឲ្យអនុវត្តរវាងថ្នាក់រាជធានី-ខេត្ត និងថ្នាក់កណ្តាល) និងការរៀបចំប្រព័ន្ធអភិបាលរបស់ថ្នាក់កណ្តាលដល់មន្ទីរពេទ្យទាំងអស់ ។ នៅព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវបានដាក់ឲ្យអនុវត្តតាមមន្ទីរពេទ្យបង្អែកកម្រិត៣ និងមន្ទីរពេទ្យជាតិមជ្ឈមណ្ឌលជាតិដោយមានការគាំទ្រពីក្រុមរោងជាងជាតិ ថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យដែលជាអង្គភាពអភិបាលថ្នាក់កណ្តាល។

## ៥. ៣ បណ្តាញគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

ដោយមានការសហការជាមួយគម្រោង MEDEM-2 ក្រសួងសុខាភិបាលបន្តពង្រីកប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរហូតដល់មន្ទីរពេទ្យបង្អែកកម្រិត២ ដើម្បីពង្រឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ និងស្ថានភាពដំណើរការរបស់ប្រព័ន្ធនេះ។ទាក់ទងនឹងសកម្មភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរបស់មន្ទីរពេទ្យបង្អែកកម្រិត២ (ក្រោមសកម្មភាពអនុវត្តសាកល្បង មន្ទីរពេទ្យបង្អែកកម្រិត៣ត្រូវបានឲ្យឈ្មោះថាជាមន្ទីរពេទ្យបង្អែកកម្រិត៣ ឈានមុខ) មន្ទីរពេទ្យបង្អែកកម្រិត៣មានភារកិច្ចអនុវត្តមុខងាររបស់ក្រុមពេទ្យជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ ។ម៉្យាងវិញទៀត ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរវាងមន្ទីរពេទ្យបង្អែក កម្រិត ៣ឈានមុខ និងមន្ទីរពេទ្យបង្អែកកម្រិត២ដែលបានជ្រើសរើសនឹងដាក់ឲ្យអនុវត្តបន្ថែមលើទំនាក់ទំនងក្នុងចំណោមក្រុមពេទ្យជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យនិងមន្ទីរពេទ្យជាតិ/មន្ទីរពេទ្យបង្អែកកម្រិត៣ ។បច្ចុប្បន្នសមត្ថភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យមន្ទីរពេទ្យបង្អែកកម្រិត ៣ ឈានមុខ ចំនួន៥ ដែលបានជ្រើសរើសមានការរីកចម្រើនច្រើន អាចផ្តល់ការគាំទ្រ ផ្តល់ប្រឹក្សា និងអភិបាលមន្ទីរពេទ្យបង្អែកកម្រិត២ ដោយមានការណែនាំសមស្របពីក្រុមពេទ្យជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ។ ទំនាក់ទំនងរួមបញ្ចូលគ្នារវាងក្រុមពេទ្យជាងជាតិ មន្ទីរពេទ្យបង្អែកកម្រិត៣ ឈានមុខនិងមន្ទីរពេទ្យបង្អែកកម្រិត២មានឈ្មោះថា"បណ្តាញ" ។

## ៥. ៤ ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា (comprehence)

**បែបបទទំនាក់ទំនងរវាងក្រុមពេទ្យជាងជាតិ**ថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ និងមូលដ្ឋានសុខាភិបាលទាំងពីរកម្រិត (មន្ទីរពេទ្យបង្អែកកម្រិត៣ឈានមុខ និងមន្ទីរពេទ្យបង្អែកកម្រិត២ដែលបានជ្រើសរើស) ត្រូវបានរំពឹងទុកថានឹងមានដំណើរការ ។ មុខងារនៃការគាំទ្រ ផ្តល់ប្រឹក្សា និងអភិបាលទាក់ទងនឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវបានផ្តល់ជូនមន្ទីរពេទ្យបង្អែកកម្រិត៣ ឈានមុខដោយក្រុមពេទ្យជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ ហើយមន្ទីរពេទ្យបង្អែកកម្រិត២ ដែលបានជ្រើសរើសនឹងត្រូវបានគាំទ្រដោយមន្ទីរពេទ្យបង្អែកកម្រិត៣ ឈានមុខ ។

នាពេលអនាគតរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសុខាភិបាលនឹងពង្រីកបែបបទទំនាក់ទំនងនៃសកម្មភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យទៅគ្រប់មន្ទីរពេទ្យបង្អែកកម្រិត២ និងកម្រិត១ទាំងអស់ ។ ការពង្រីកបែបបទទំនាក់ទំនងប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ នៅតាមមូលដ្ឋានសុខាភិបាលក្នុងប្រទេសកម្ពុជាមានន័យថាការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យត្រូវបានពង្រឹង ។

**រូបភាព-៣: វដ្តនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ**




***រាល់នីតិវិធីទាំងអស់ សូមអានសេចក្តីណែនាំ និងឯកសារណែនាំពាក់ព័ន្ធនានា ។***

## ៥.៥ វដ្តនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

ស្តង់ដារវដ្តនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យមានបង្ហាញក្នុងតារាងខាងលើ ។ ដំណើរការនីមួយៗនៃវដ្តនេះមានពន្យល់លម្អិតក្នុងសេចក្តីណែនាំ និងឯកសារណែនាំពាក់ព័ន្ធនានា ។ វដ្តនេះចាប់ផ្តើមពីការធ្វើផែនការ(Planning) ការបែងចែកថវិកា(Budget allocation) ការធ្វើលទ្ធកម្ម(Procurement) ការដំឡើង(Installation) ការធ្វើអធិការកិច្ច(Inspection) ការប្រើប្រាស់(Operation) ការត្រួតពិនិត្យ(Checking) ការថែទាំ និងការជួសជុល(Maintanance and Repair) ។ បន្ទាប់ពីការត្រួតពិនិត្យស្ថានភាពឧបករណ៍ វដ្តនេះបន្តទៅដល់ការសុំជម្រះបញ្ជី ឬផ្លាស់ប្តូរឧបករណ៍ បន្ទាប់មកទៀតវដ្តនេះនឹងវិលទៅដំណាក់កាលនៃការធ្វើផែនការម្តងទៀត ។នៅពេលចាប់ផ្តើមប្រើប្រាស់ឧបករណ៍ ដំបូងតម្រូវឲ្យមានការបណ្តុះបណ្តាលអ្នកប្រើប្រាស់ និងការបណ្តុះបណ្តាលបន្ត ឬវគ្គបំប៉នគួររៀបចំឡើងក្នុងកំឡុងពេលដំណើរការឧបករណ៍ប្រសិនបើចាំបាច់ ។ ការគ្រប់គ្រងរដ្ឋបាលមានបង្ហាញនៅក្នុងរូបភាព-៣ ។

| ➢ បញ្ជីសារពើភ័ណ្ឌឧបករណ៍បរិក្ខារពេទ្យ |
| --- |
| សារពើភ័ណ្ឌនៃឧបករណ៍បរិក្ខារពេទ្យដែលត្រឹមត្រូវនិងជាក់ស្តែងគឺជាមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យបែបវិទ្យាសាស្ត្រ ។បច្ចុប្បន្ន មន្ទីរពេទ្យបង្អែកកម្រិត៣តម្រូវឲ្យមានការត្រួតពិនិត្យស្ថានភាពឧបករណ៍ និងស្ថានភាពប្រើប្រាស់ចំនួន២ដង ក្នុង១ឆ្នាំដោយក្រុមការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ហើយគាត់ត្រូវបញ្ជូនសារពើភ័ណ្ឌនេះទៅក្រុមរោងជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យ (នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល)នៅខែឧសភា និងខែវិច្ឆិកាតាមកាលវិភាគដែលបានកំណត់ ។ នៅដំណាក់កាលដំបូង គម្រោង MEDEM-1 បានណែនាំទម្រង់បញ្ជីសារពើភ័ណ្ឌ បន្ទាប់មកប្រព័ន្ធនេះបានផ្សព្វផ្សាយជាផ្លូវការទៅគ្រប់មន្ទីរពេទ្យបង្អែកកម្រិត៣ទាំងអស់ នៅឆ្នាំ ២០០៧ ។ សារពើភ័ណ្ឌនេះគួរចែករំលែកជាមួយប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត មន្ទីរពេទ្យនិងដៃគូអនុវត្តពាក់ព័ន្ធដទៃទៀតដើម្បីឲ្យបានយល់ពីស្ថានភាពជាក់ស្តែងរបស់ឧកបករណ៍បរិក្ខារពេទ្យនៅតាមមន្ទីរពេទ្យនីមួយៗ និងចាត់វិធានការ |

សមស្របតាមវដ្តនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។

## ៦. ស្តង់ដារផ្នែកវិស្វកម្ម/ពេទជាង

### ៦.១. ផ្នែកវិស្វកម្ម /ពេងជាង

គ្រឹះស្ថានសុខាភិបាលមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិនិងមន្ទីរពេទ្យបង្អែកកម្រិត៣/២/១ ត្រូវមានផ្នែកវិស្វកម្ម / ពេងជាងសមស្របតាមការណែនាំដែលមានលក្ខណៈដូចខាងក្រោម ៖

- ពេងជាងត្រូវមានទំហំយ៉ាងតិច ២៥ ម៉ែត្រការ៉េ
- តុសម្រាប់ធ្វើការថែទាំជួសជុលតូច និងធ្វើការងាររដ្ឋបាល
- ប្រព័ន្ធទឹកមានក្បាលរ៉ូប៊ីណេ និងឡាវ៉ាបូសម្រាប់ប្រើប្រាស់
- ធ្នើរដែកឬឈើសម្រាប់ដាក់ឧបករណ៍
- ទូសម្រាប់ដាក់ឯកសារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

### ៦.២. ការទទួលខុសត្រូវ

នាយក ឬប្រធានអង្គភាពសាមីៈ

- ត្រូវសហការជាមួយក្រុមពេងជាងជាតិដើម្បីបង្កើតផ្នែកវិស្វកម្ម / ពេងជាងឲ្យបានសមស្រប ។
- ត្រូវមានផែនការថវិកាអាទិភាពប្រចាំឆ្នាំសម្រាប់ដំណើរការផ្នែកវិស្វកម្ម/ពេងជាង ។
- ត្រូវអភិបាលនិង ត្រួតពិនិត្យទៀងទាត់អំពីដំណើរការផ្នែកវិស្វកម្ម/ពេងជាង។

## ៧. និរន្តរភាពថវិកាសម្រាប់សកម្មភាពគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

ត្រូវមានធនធានថវិកា ឬការបែងចែកថវិកានៅគ្រប់កម្រិតដើម្បីធានាគុណភាពនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅគ្រប់កម្រិត និងនៅគ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ ។ ការបង្កើតឲ្យមានការគ្រប់គ្រងថវិកានឹងបង្កើនប្រសិទ្ធិផល និងប្រសិទ្ធិភាពនៃការប្រើប្រាស់ថវិកាដែលមាន រួមទាំងថវិកាក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ និងប្រាក់ហិរញ្ញប្បទាននៅគ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ ។យោងតាមបទពិសោធន៍របស់គម្រោង MEDEM-1 និង MEDEM-2 ការផ្តល់ថវិកាសមស្របតាមសំណើក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំគឺជាប្រភពដ៏ល្អបំផុតដើម្បីទ្រទ្រង់កម្មវិធី និងសកម្មភាពរបស់មន្ត្រីសុខាភិបាលដែលធ្វើការងារគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។

( ១ ) យន្តការថវិកាតាមរយៈផែនការប្រតិបត្តិការប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យជាការងារអាទិភាព

ត្រូវបែងចែកថវិកាសមស្របដល់គ្រប់កម្រិតទាំងអស់តាមរយៈផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីឲ្យមាននិរន្តរភាពនៃថវិកាជាក់ស្តែង ។ ថវិកាប្រចាំឆ្នាំអាចជាសកម្មភាពមួយទាក់ទងនឹងសកម្មភាពនៅគ្រប់ថ្នាក់ទាំងអស់ដូចជាថ្នាក់កណ្តាល មន្ទីរសុខាភិបាលរាជធានី-ខេត្ត ស្រុកប្រតិបត្តិ ក៏ដូចជាមូលដ្ឋានសុខាភិបាល។ដូច្នេះហើយគួរមានការបែងចែកថវិកាឲ្យបានទៀងទាត់ និងសមស្របបំផុត ។ ក្រោមកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទី២ និងផែនការយុទ្ធសាស្ត្រសុខាភិបាលដំណាក់កាលទី២ ថវិកាមួយចំនួនត្រូវបានចែកជូនជា

បណ្ដោះអាសន្ន ។ការបែងចែកថវិកាឲ្យបានទៀងទាត់គួរត្រូវបានអនុវត្តដើម្បីនិរន្តរភាពនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។

ក្រោមគម្រោង MEDEM-1 និង MEDEM-2 យន្តការថវិកាពឹងផ្អែកលើធនធានដូចខាងក្រោម៖

- ថវិការដ្ឋផ្ដល់ជូនតាមរយៈ**ផែនការប្រតិបត្តិប្រចាំឆ្នាំ**ដែលរៀបចំឡើងដោយមន្ទីរសុខាភិបាលរាជធានី-ខេត្ត ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែក ។
- ជំនួយ និងមូលនិធិពីដៃគូអភិវឌ្ឍនានា
- ចំណូលពីសកម្មភាពផ្សេងៗក្នុងមូលដ្ឋានសុខាភិបាលមានដូចជាប្រាក់ហិរញ្ញប្បទាន ។

សកម្មភាពមានស្ថេរភាពដំបូងគឺពឹងផ្អែកសំខាន់ទៅលើរចនាសម្ព័ន្ធថវិកាមានស្ថេរភាពនៅគ្រប់កម្រិតទាំងអស់សម្រាប់បុគ្គលិកដែលពាក់ព័ន្ធនានា ដូចជាប្រធានគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ និងអ្នកបច្ចេកទេសថែទាំឧបករណ៍បរិក្ខារពេទ្យ ព្រមទាំងសម្រាប់ការថែទាំ និងជួសជុល ។

## ៨. សេចក្តីណែនាំ និងឯកសារណែនាំសម្រាប់ការគ្រប់គ្រង និងថែទាំឧបករណ៍បរិក្ខារពេទ្យ

គម្រោង MEDEM-1 និង MEDEM-2 សហការជាមួយក្រុមរោងជាងជាតិថែទាំជួសជុលឧបករណ៍បរិក្ខារពេទ្យបានបង្កើតសេចក្តីណែនាំ និងឯកសារណែនាំដែលពាក់ព័ន្ធនានាតាំងពីឆ្នាំ២០០៦។ ត្រូវបង្កើតឲ្យមានឯកសារថ្មីៗ និងកែសម្រួលឯកសារដែលមានស្រាប់យោងតាមតម្រូវការ និងដំណើរការកម្មវិធីនិងសកម្មភាពនៃការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ ។ គោលនយោបាយ សេចក្តីណែនាំនិងបទដ្ឋានគតិយុត្តិនានាត្រូវប្រើប្រាស់ក្នុងពេលដំណាលគ្នាជា "កញ្ចប់តែមួយ" ។

(សូមអានឧបសម្ព័ន្ធ-២: បញ្ជីឈ្មោះសេចក្តីណែនាំ ឯកសារណែនាំសំខាន់ៗនិងរបាយការណ៍ទាក់ទងនឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ) ។

- **ការកែសម្រួល និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងយុទ្ធសាស្ត្ររយៈពេលវែង**

ឯកសារគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យរយៈពេលវែងត្រូវកែសម្រួលទៅតាមដំណាក់កាលនៃការអភិវឌ្ឍវិស័យសុខាភិបាល។ ត្រូវត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយជាតិនៅរៀងរាល់ ៣ ឆ្នាំម្តង ។ គោលនយោបាយជាតិនេះអាចកែសម្រួលតាមតម្រូវការចាំបាច់ដោយ**គណៈកម្មការរៀបចំគោលនយោបាយ** ក្នុងនោះផ្តោតទៅលើការផ្លាស់ប្តូររចនាសម្ព័ន្ធ ឬការផ្លាស់ប្តូរសំខាន់ៗក្នុងក្រសួងសុខាភិបាល និងលទ្ធភាពនៃសំណើសុំកែសម្រួលបន្ថែមពីកម្រិតរដ្ឋបាលពាក់ព័ន្ធផ្សេងៗ ចាប់ពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។

# ឯកសារយោង


1. រដ្ឋធម្មនុញ្ញនៃរាជរដ្ឋាភិបាលកម្ពុជា មាត្រាទី៧២
2. ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលលើកទី២ (២០០៨-២០១៥)-ការទទួលខុសត្រូវ ប្រសិទ្ធិភាព គុណភាព សមធម៌ ខែមេសា ឆ្នាំ២០០៨ របស់ក្រសួងសុខាភិបាល
3. ឯកសាររបស់គម្រោងមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក គម្រោង MEDEM-1 និង MEDEM-2 (២០០០-២០១១) រួមទាំងរបាយការណ៍វាយតម្លៃពាក់កណ្តាលគម្រោង និងរបាយការណ៍បញ្ចប់គម្រោងរបស់អង្គការ JICA ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា ។
4. ឯកសារគោលនយោបាយ: ការជួសជុលនិងថែទាំឧបករណ៍បរិក្ខារពេទ្យដែលចេញផ្សាយលើកទី១នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០ របស់នាយកដ្ឋានមន្ទីរពេទ្យ/អគ្គនាយកបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល។
5. សេចក្តីណែនាំ និងផែនការអនុវត្ត: ការជួសជុលនិងថែទាំឧបករណ៍បរិក្ខារពេទ្យ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០០
6. ការថែទាំជាមូលដ្ឋាន: ការជួសជុលនិងថែទាំឧបករណ៍បរិក្ខារពេទ្យថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០០
7. គោលនយោបាយជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ ចេញផ្សាយនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងសុខាភិបាល
8. ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ត្រួតពិនិត្យការចម្លងរោគនៅតាមមូលដ្ឋានសុខាភិបាល (២០១១-២០១៥) ខែសីហា ឆ្នាំ២០១០ របស់ក្រសួងសុខាភិបាល
9. គោលនយោបាយជាតិស្តីពីការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ របស់នាយកដ្ឋានសេវាមន្ទីរពេទ្យនៃក្រសួងសុខាភិបាល ឧបត្ថមដោយដោយអង្គការសុខភាពពិភពលោក

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមក្រសួងសុខាភិបាលនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ និងជានាយកគម្រោង MEDEM ខ្ញុំសូមថ្លែងអំណរគុណចំពោះការរួមចំណែកទាំងផ្នែករដ្ឋបាល និងបច្ចេកទេសដ៏មានតម្លៃរបស់ដៃគូទាំងពីរដែលបានធ្វើការរួមគ្នាក្នុងគម្រោង MEDEM-1 និងMEDEM-2 ដើម្បីរៀបចំ**សេចក្តីព្រាងគោលនយោបាយជាតិសម្រាប់ប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យនៅកម្ពុជា**។

- **ក្រុមការងារបច្ចេកទេសរៀបចំឯកសារនេះ:**

**1. សមាជិកកម្ពុជា**:

- ✧ លោកវេជ្ជ. សុខ ស្រ៊ុន ប្រធាននាយកដ្ឋានមន្ទីរពេទ្យ
- ✧ លោកវេជ្ជ. គឹមសាវួន អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ
- ✧ លោកវេជ្ជ. ជី ស៊ីវុទ្ធី ប្រធានការិយាល័យសេវាមន្ទីរពេទ្យនិងជីវៈវិស្វកម្មវេជ្ជសាស្ត្រនាយកដ្ឋានមន្ទីរពេទ្យនិងអនុប្រធានក្រុមរោងជាងជាតិ (ទទួលបន្ទុកកិច្ចការរដ្ឋបាល)
- ✧ លោកគ្រូពេទ្យ ហួត ខុមអនុប្រធានក្រុមរោងជាងជាតិ (ទទួលបន្ទុកកិច្ចការបច្ចេកទេស)
- ✧ សមាជិកក្រុមរោងជាងជាតិទាំងអស់មកពីមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល
- ✧ លោកវេជ្ជ.សាន់ សារី អតីតប្រធាននាយកដ្ឋានមន្ទីរពេទ្យ

**2. សមាជិកជប៉ុន:**

១. លោក Takeshi Matsuo ប្រធានទីប្រឹក្សានិងជំនាញការផ្នែកគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ គម្រោង MEDEM

២. លោក Ryoichi Suzuki អនុប្រធានទីប្រឹក្សានិងជំនាញការផ្នែកគ្រប់គ្រង និងរដ្ឋបាលសុខភាព គម្រោង MEDEM

៣.លោក Kazushiro Suzuki ជំនាញការផ្នែកថែទាំឧបករណ៍បរិក្ខារពេទ្យ គម្រោង MEDEM

៤. លោក Tamotsu Nozaki ជំនាញការផ្នែកប្រព័ន្ធគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ គម្រោង MEDEM

# ✧ ឧបសម្ព័ន្ធ-១: ឯកសារណែនាំ និងសេចក្តីណែនាំពាក់ព័ន្ធនឹងការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ

| ឆ្នាំ | ចំណងជើង |
|---|---|
| ២០០៨ | ➢ សេចក្តីណែនាំស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យសម្រាប់មន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យបង្អែក CPA3 (ខ្មែរ និងអង់គ្លេស) ឆ្នាំ ២០០៨<br>➢ ឯកសារណែនាំស្តីពីរបៀបរៀបចំវគ្គបណ្តុះបណ្តាល ឆ្នាំ ២០០៨<br>➢ សៀវភៅមគ្គុទេសក៏សម្រាប់ការថែទាំឧបករណ៍បរិក្ខារពេទ្យផ្នែក A (ខ្មែរ និងអង់គ្លេស) ឆ្នាំ ២០០៨<br>➢ សៀវភៅមគ្គុទេសក៏សម្រាប់ការថែទាំឧបករណ៍បរិក្ខារពេទ្យផ្នែក B (ខ្មែរ និងអង់គ្លេស) ឆ្នាំ ២០០៨ |
| ២០១០ | ➢ សៀវភៅមគ្គុទេសក៏សម្រាប់ការថែទាំឧបករណ៍បរិក្ខារពេទ្យផ្នែក B សម្រាប់ឧបករណ៍បន្ថែម (ខ្មែរ និងអង់គ្លេស) ឆ្នាំ ២០១០ |
| ២០១១ | ➢ សេចក្តីណែនាំស្តីពីការសុំជម្រះបញ្ជីឧបករណ៍បរិក្ខារពេទ្យតាមលក្ខណៈបច្ចេកទេស (ខ្មែរ និងអង់គ្លេស) ឆ្នាំ ២០១១<br>➢ សេចក្តីណែនាំសម្រាប់អនុវត្តបណ្តាញគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យសាកល្បង (ខ្មែរ និងអង់គ្លេស) ឆ្នាំ ២០១១<br>➢ សេចក្តីណែនាំផ្នែកបច្ចេកទេសសម្រាប់ការទទួលឧបករណ៍បរិក្ខារពេទ្យដែលគេប្រើហើយ (ខ្មែរនិងអង់គ្លេស) ឆ្នាំ ២០១១ |